ថ្ងៃសុក្រ ០៧ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១៨

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការពង្រឹងការអនុវត្តកាតព្វកិច្ចរបស់ភ្នាក់ងារសេវាកម្មពន្ធដារ"




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ៨:៣០នាទីព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ នៅសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការពង្រឹង ការអនុវត្តកាតព្វកិច្ចរបស់ភ្នាក់ងារសេវាកម្មពន្ធដារ" ដល់ក្រុមហ៊ុនដែលបំពេញសេវាកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ ចំនួន ១០០ ក្រុមហ៊ុន ក្រោមអធិបតីភាពរបស់ឯកឧត្តម **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមរបស់ថ្នាក់ដឹកនាំ នាយកដ្ឋាន មន្ត្រីពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើមឯកឧត្តមអេងរតនា បានសម្តែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន ថ្នាក់ដឹកនាំនាយកដ្ឋាន មន្ត្រីពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងក្រុមហ៊ុនភ្នាក់ងារសេវាកម្មពន្ធដារ និងសម្តែងការកោតសរសើរ ចំពោះសហគ្រាសភ្នាក់ងារសេវាកម្មពន្ធដារ ដែលបានយកចិត្តទុកដាក់គោរពច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ជាពិសេសអនុវត្តបានតាមប្រកាសស្តីពីភ្នាក់ងារសេវាកម្មពន្ធដារ និងសេចក្តីជូនដំណឹងស្តីពីការស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ។

ភ្នាក់ងារសេវាកម្មពន្ធដារនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយអ្នកជាប់ពន្ធ ឲ្យគោរពប្រតិបត្តិច្បាប់បានត្រឹមត្រូវ និងជួយលើកកម្ពស់វប្បធម៌ នៃការបង់ពន្ធឲ្យកាន់តែប្រសើរ។ ជាងនេះទៅទៀតភ្នាក់ងារសេវាកម្មពន្ធដារគឺជាអ្នកផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្នកជាប់ពន្ធ ជាមួយរដ្ឋបាលសារពើពន្ធក្នុងការបំពេញបែប

បទដាក់លិខិតប្រកាសសារពើពន្ធ ប្រចាំខែ ប្រចាំឆ្នាំ និងបង់ពន្ធ-អាករទាំងឡាយ បង្ហាញ និងផ្តល់ឯកសាររបាយការណ៍ និងលិខិតគតិយុត្តផ្សេងៗរបស់អ្នកជាប់ពន្ធ ពាក់ព័ន្ធនឹងពន្ធដារជូនរដ្ឋបាលសារពើពន្ធស្របតាមបទប្បញ្ញត្តិនានាស្តីពីពន្ធដារ បំពេញរាល់កាតព្វកិច្ច ដែលអ្នកជាប់ពន្ធត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ទទួលព័ត៌មានជាប្រចាំ អំពីការធ្វើបច្ចុប្បន្នភាព ឬវិសោធនកម្មច្បាប់ និង បទប្បញ្ញត្តិនានាស្តីពីពន្ធដារ ជាដៃគូសហប្រតិបត្តិការល្អជាមួយរដ្ឋបាលសារពើពន្ធ ក្នុងការពង្រីក និងពង្រឹងការផ្តល់សេវា ការអប់រំដល់អ្នកជាប់ពន្ធ ធានាឲ្យបានការអនុវត្តច្បាប់ ព្រមទាំងទប់ស្កាត់សកម្មភាពគេចវេះពន្ធផងដែរ។

នៅក្នុងអង្គពិធីនេះ ឯកឧត្តម អេង រតនា ក៏បានផ្តាំផ្ញើដល់ក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណ ភ្នាក់ងារសេវាកម្មពន្ធដារ ដែលជាអ្នកផ្តល់សេវាកម្មផ្នែកពន្ធដារ ត្រូវប្រើប្រាស់ជំនាញវិជ្ជាជីវៈរបស់ខ្លួនឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់ គោរពតាមក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងជួយអ្នកជាប់ពន្ធដទៃទៀតឲ្យគោរពច្បាប់បានត្រឹមត្រូវ លើកកម្ពស់វប្បធម៌នៃការបង់ពន្ធឲ្យកាន់តែទូលំទូលាយ ក្នុងគោលដៅចូលរួមចំណែកកែទម្រង់ប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធឲ្យកាន់តែទទួលលទ្ធផលល្អប្រសើរ។ ឯកឧត្តម ក៏បានក្រើនរំលឹកដល់ លោក-លោកស្រី ឬសហគ្រាសទាំងអស់ដែលកំពុងធ្វើ ឬមានបំណងធ្វើសកម្មភាពជាភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ឲ្យបានរួសរាន់។ ក្នុងករណីលោក-លោកស្រី ឬសហគ្រាសធ្វើសកម្មភាពអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារ ដោយគ្មានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវទទួលរងពិន័យ ៥ 000 000 រៀល ដល់ ១0 000 000 រៀល ឬជាប់ពន្ធធនាគារ ពី១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ។

ជាទីបញ្ចប់ ឯកឧត្តម អេង រតនា បានជូនពរ ឯកឧត្តម លោក-លោកស្រីទាំងអស់ ដែលមានវត្តមាននៅទីនេះ សូមសមប្រកបនឹងពុទ្ធពរទាំង ៤ ប្រការ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ